## កាទូច
## បុរេកថាឬកាផ្ដើម

> A martial artist has to take responsibility for himself…
> And to accept the consequences of his own doing.
>
> Bruce Lee, Enter the Dragon

គេថារស់ម៉ាជាតិធាតុម៉ាចាន ងាប់ទៅវិញយកមិនបាន តើទៅខ្វល់បានប្រយោជន៍អី? ទីបំផុតខ្ញុំងាប់មែន។ មានគេសួរខ្ញុំថា តើខ្ញុំមកស្រុកខ្មែរនេះធ្វើអ្វីដែរ? ខ្ញុំធ្លាប់ឆ្លើយប្រាប់គេថា ខ្ញុំមកស្រុកខ្មែរដើម្បីសរសេរសៀវភៅមួយ។ ឥឡូវចំលើយដែលត្រូវបំផុតនោះគឺ ខ្ញុំមកដើម្បីអោយគេសំលាប់។ ទោះចង់ឬមិនចង់តើមាននរណាអាចហាមឃាត់សេចក្ដីស្លាប់បាន? គ្រាន់ថាស្លាប់ក្រោមដៃអ្នកដទៃធ្វើអោយយើងបិទភ្នែកមិនជិតប៉ុណ្ណឹង។ ជាពិសេសយើងមិនបានធ្វើខុសអីសោះនៅសុខៗស្រាប់តែគេមកយកជីវិតយើងទទេ។

ទោះនៅសល់ដង្ហើមផ្ដឹកៗចុងក្រោយនេះក៏ដោយ ខ្ញុំសូមជូនរឿងខ្លីមួយ។ រឿងនេះមិនវែងហើយក៏មិនខ្លី ខ្ញុំលកលៃយ៉ាងណា មុននឹងងាប់ដាច់ខ្យល់រៀបរាប់អោយអស់សេចក្ដី។

មុននឹងមកដល់ស្រុកខ្មែរ ខ្ញុំប្រាថ្នាសរសេរសៀវភៅថ្មីមួយពីស្រុកខ្មែរ។ ខ្ញុំចង់សរសេរពីរឿងស្នេហា ខ្ញុំមិនសរសេរទេរឿងប្រឡាក់ឈាម។ តែខ្ញុំនៅតែជៀសមិនផុតព្រោះតែចរិកខ្មែរនៅតែដដែល មិនកែទៅណាសោះ។ សៀវភៅនេះនៅតែប្រឡាក់ទៅដោយឈាម។

ទោះយ៉ាងណា ភាគច្រើននៃរឿងបានព្យាយាមរៀបរាប់ពីជីវិតថ្មី លើទឹកដីកម្ពុជានិងស្នេហាមួយដែលពិបាកនិងសរសេររៀបរាប់។ តើអ្នកសង្ឃឹមថាពាក្យពេចន៍អាចរៀបរាប់ពីមនោសញ្ចេតនា ដែលកប់ជ្រៅក្នុងក្រអៅបេះដូងយើងបានប៉ុន្មាន



ភាគរយ? ពាក្យពេចន៍ដែលខ្ញុំផ្សំផ្គុំក្នុងពេលនេះព្រោះចង់អធិប្បាយពីរឿងរ៉ាវស្នេហាមួយ។ តែថាទៅ ពាក្យពេជន៍មិនអាចរៀបរាប់ពីមនោសញ្ចេតនារបស់មនុស្សលោកបានអស់ឡើយ។ ចាត់ទុកថាជាការសាកល្បងមួយទៅចុះ ដោយខ្ញុំមានពេលមិនច្រើន តទៅនេះសូមរៀបរាប់តាមដំនើរដើមទងរឿងកាទូច។

## កាទូច
## វគ្គទីមួយ

ម៉ោងបួនទៀបភ្លឺ មាន់រងាវពេញភូមិ។ កាទូចរូតរះភ្ញាក់ពីដំនេក ដើបទៅអុចចង្កៀងប្រេងកាតហើយកាន់ចុះទៅលុបមុខលុបមាត់ នៅពាងក្រោមផ្ទះ។ លុះចប់ភារះនាងយួរទឹកមួយប៉ោតឡើងទៅចង្ក្រាន ដើម្បីដាំបាយរៀបចំម្ហូបអាហារទៅស្រែ។ នៅកាំជន្ដើរខាងមុខផ្ទះរណោះ អ៊ំថនត្រូវជាពុកកាទូចមិនដឹងគាត់ភ្ញាក់តាំងពីអង្កាលមកដែរ កំពុងអង្គុយមូរបារីស្លឹកសង្កែ ញាប់ដៃស្មេរព្រោះតែជូរមាត់។ មីងសួនប្រពន្ធអ៊ំថនហើយត្រូវជាម៉ែកាទូចដែរនោះ បន្ទាប់ពីរៀបចំកន្ទេលខ្នើយរួចរាល់ ក៏ចូលខ្លួនទៅជួយកូននៅចង្ក្រាន។ ធាតុអាកាសត្រជាក់ស្រិប កំពុងគ្របដណ្ដប់ភូមិព្រៃកប្រសប់ទាំងមូល។ ព្រៃកប្រសប់ជាភូមិមួយនៅក្នុងខេត្តក្រចេះ ជាធម្មតានៅភូមិភាគឦសានតែងតែត្រជាក់ជាងនៅភូមិភាគដទៃទៀត។ ថ្មើរនេះអ្នកភូមិខ្លះ កំពុងតែអង្កុញជើងជ្រកខ្លួននៅក្នុងភួយ ដេកឆ្ងាញ់ភ្នែកនៅឡើយ។ លើកលែងតែគ្រួសារខ្លះ ដែលត្រូវរៀបចំបាយទឹកសំនុំទៅស្រែ តួយ៉ាងដូចគ្រួសារអ៊ំថនជាដើម។

អ៊ំថនមីងសួន មានកូនបង្កើតបីនាក់និងកូនចិញ្ចឹមមួយ។ កាទូចជាកូនស្រីច្បងលុះនាងនោះធំពេញក្រមុំ ល្មមគ្រប់អាយុការចាស់ទុំទាំងពីរមូលមិតិគ្នា លើកកូនស្រីបង្កើតខ្លួនទៅអោយកូនចិញ្ចឹម ដែលរស់នៅជាមួយខ្លួនតាំងពីតូចក្រូចឆ្មារមក។ កនជាកូនកំព្រា តែជាក្មេងឧស្សាហ៍ព្យាយាម បានគ្រួសារអ៊ំថនចិញ្ចឹមបីបាច់ហើយផ្ដល់ការទុកចិត្តលើកកូនស្រីអោយទៀត។ កាទូចនិងកន រៀបការបានកូនស្រីមួយអាយុជាងពីរខួប។ កនពូកែលើការងារដីស្រែ រែកទឹកពុះអុស អោយតែការងារ

ប្រុសៗគាត់នោះចេះទាំងអស់ តាំងពីដើមដល់ចប់។ អពភ្ញ័អី រដូវចុងក្រោយនេះ ដោយសារគ្រោះធម្មជាតិ ខ្វះទឹកដាក់ស្រែ ផលស្រូវដែលបានមកមិនគ្រប់ល្មមនឹងផ្គត់ផ្គង់គ្រួសារ។ កនដាច់ចិត្ត មករកការងារធ្វើនៅភ្នំពេញចោលប្រពន្ធនិងកូននៅឯស្រែ។ កាទូចអត់ពីប្ដីទៅ ត្រូវរ៉ាប់រងការងារជាច្រើនជំនួសប្ដី ណាមើលស្រែ ណាមើលថែកូន ណារៀបចំបាយទឹក ណាសំអាតផ្ទះសំបែង ម្ទៃៗនាងនោះរវល់តាំងពីព្រឹកទល់យប់។ យូរៗម្ដងទើបឃើញប្ដីមកលេង ជួនក៏មិនបានឃើញទៅទៀត ឃើញតែលុយដែលផ្ញើរមក តាមឡានតាក់ស៊ី។ ហើយការដែលចំលែកទៅទៀតនោះ ពីរបីខែចុងក្រោយនេះ បាត់ដំនឹងកនសូន្យឈឹង។ មនុស្សក៏មិនឃើញលុយក៏មិនបានទទួល។

កាទូចកំពុងតែចិញ្ចាំប្រហុក ដើម្បីខ្ចប់អាំងនិងស្លឹកចេក។ មីងសួនរៀបចំចានក្បានដាក់ស្ពឺបណ្ដើរ ឆ្លៀតសួរទៅកូនបណ្ដើរ៖

-កូនមានស៊ើបសួរតាក់ស៊ីខ្លះទេ? ក្រែងបានដំនឹងពីអាកន

-សួរហើយម៉ែ អាម៉ាប់វាប្រាប់ថា បងកនឈប់ធ្វើការ នៅកន្លែងធ្វើឡានហើយ។

-យីអានេះ ទៅណាម៉ោណា ម៉េចវាមិនអោយដំនឹងមកផ្ទះ?

-កូនមិនដឹងថាពិតអត់ គេថាបងកនល្ហក់ចាក់បាល់ ចាញ់លុយជំពាក់គេវិលក្បុង

-អើអញថាអីចេះខុស អាល្បែងស៊ីសង វាមិនខុសអីពីយកលុយទៅអោយគេ។ ឥលូវឃើញទេ តើវារត់ខ្ចត់ព្រាត់ទៅឯណាហើយ?

-គាត់ទៅសំងំរកលុយណឹងម៉ែ មិនយូរមិនឆាប់គាត់ត្រលប់វិញហើយ

-អើអញចេះតែបារម្ភ

ម៉ែកូនទាំងពីររៀបចំបាយទឹកបណ្ដើរ ត្អូញត្អែរពីកនបណ្ដើរ។ នៅឯក្បាលជន្ទើរខាងមុខ អ៊ំថនកំពុងស្ដាប់វិទ្យុ ក្លែមជាមួយផ្សែងបារីមូរដៃរបស់គាត់។ លុះភ្លឺស្រាងៗ អ្នកទាំងបីប្រញាប់ប្រញាលចេញដំនើរទៅស្រែ។ ក្មេងៗ ត្រូវជាប្អូនកាទូច ត្រូវកាទូចដាស់ ភ្ញាក់ទាំងមមើរមម៉ាយ អោយមើលផ្ទះនិងក្មួយដែលកំពុងដេក



លក់នៅឡើយ។ ដល់ស្រែសឹងមិនទាន់ អ៊ំថនលាត់ជើងខោ ទៅពិនិត្យទឹកស្រែ។ វស្សាដល់ហើយ ម្ដេចឡើយមិនភ្លៀង? ស្រូវប្រាកដជាស្កក បើសិនជាគ្មានទឹកបញ្ចូលស្រែ។ អ៊ំថនចាប់ផ្ដើមខ្វល់ខ្វាយ រកកលដោះស្រាយ ដើម្បីបានទឹកដាក់ស្រែ។ មើលទៅទំនប់គ្មានទឹកមួយដំនក់ បើដេកសង្ឃឹមភ្លៀងមិនដឹងថ្ងៃណា។ ទាល់តំរេះ លុះដល់វេលាបាយថ្ងៃត្រង់ អ៊ំថនពិភាក្សានិងប្រពន្ធកូនថា៖

-ម៉ែវាបើសិនជាគ្មានទឹក បញ្ចូលស្រែអាទិត្យក្រោយទេ ស្រូវយើងពិតជាស្កកហើយ

-ទំនប់ទឹកយើងរីងទៅហើយ បឹងប៉ោងដែលនៅសល់ទឹក នៅឆ្ងាយទៅទៀត។

-យើងចាំបាច់ត្រូវរកទិញ ម៉ាស៊ីនបូមទឹកមួយហើយ។ បូមពីបឹងប៉ោងទំលាក់ទំនប់ ហើយចាំបង្ហូរពីទំនប់ចូលស្រែ។

-មានតែផ្លូវមួយណឹងឯង តែថ្លៃណាស់ពុកវាអើយ ខ្ញុំគ្មានលុយទេ។

-កូនចង់ទៅភ្នំពេញ ទៅតាមរកបងកន ក្រែងគាត់មានលុយ គ្រាន់នឹងទិញម៉ាស៊ីនបូមទឹកមួយ។

-តើកូនទៅរកវានៅឯណាឃើញ? អាចោរម្សៀតនោះវាងប់នឹងល្បែង តើកូនសង្ឃឹមថាវាសល់លុយដែរ?

-ទោះយ៉ាងណា កូនត្រូវទៅតាមរកគាត់ដែរ បានលុយឬមិនបាន កូនត្រូវនាំគាត់មកផ្ទះយើងវិញ។

-ពុកវា កាទូចវានិយាយត្រូវ បណ្ដោយអាកននៅក្រុងយូរខូចខ្លួនអស់។ នាំវាត្រលប់មកផ្ទះវិញ គ្រាន់ជួយការងារពុកវាឯងដែរ។

-អើអញមិនជំទាស់អីទេ តែថាកូនទៅរកវានៅឯណា? ភ្នំពេញធំណាស់កូនអើយ

-បើសួរនាំពួកម៉ាកគាត់ នៅកន្លែងធ្វើឡានចាស់ ច្បាស់ជាបានតំរុយខ្លះមិនខាន។

-កូនគិតទៅប៉ុន្មានថ្ងៃ? ហើយទៅដេកពួនឯណា?

-អាម៉ាប់វាធានាជូនខ្ញុំពុក វាថាដេកលើឡានវាក៏បានដែរ វាអត់គិតលុយកាក់អីទេ។ កូនទៅតែមួយយប់ទេ កូនត្រលប់មកវិញហើយ។

-អើទៅចុះ ហើយប្រយត្ន័ប្រយែងផង

-ចាស់ពុក

បន្ទាប់ពីមូលមិតិគ្នាហើយ អ្នកទាំងបីក៏ចាប់ផ្តើមបរិភោគ អាហារថ្ងៃត្រង់ក្រោមដើមរាំង ក្លិនប្រហុកអាំងហើរសាយភាយពេញវាលស្រែ។

## កាទូច
## វគ្គទីពីរ

កាទូចមកដល់ភ្នំពេញ តាមឡានតាក់ស៊ីរបស់នាយម៉ាប់។ នាយម៉ាប់ កននិងកាទូចស្និទ្ធស្នាលនិងគ្នាគួរសមដែរ ព្រោះជាក្មេងភូមិតែមួយ ធ្លាប់រៀនជាមួយគ្នាហើយត្រូវរំពាត់អ្នកគ្រូម៉ាក់ស៊ីដូចគ្នា។ លុះមានប្រពន្ធកូន ក៏រវល់រៀងៗខ្លួន មិនសូវជាបានស្និទ្ធស្នាលគ្នាដូចមុន។ តែពួកគេតែងតែជួយគ្នាពេលមានអាសន្ន តួយ៉ាងដូចជាពេលនេះជាដើម។ នាយម៉ាប់ដាក់ភ្ញៀវចុះ ស្រួលបួលហើយក៏នាំកាទូចទៅស៊ើបសួរដំនឹងកន នៅកន្លែងធ្វើឡានម្តុំផ្សារដេប៉ូ។ កំពុងបើកឡានសុខៗ ស្រាប់តែមានឡានមួយបើកវ៉ាពីខាងស្តាំលឿនស្លេវ។ នាយម៉ាប់ហួសចិត្ត វេឡានខ្លួនទៅឆ្វេងទុកផ្លូវអោយឡានអ្នកឈ្លើយទៅមុន។
នាយម៉ាប់រអ៊ូរប្រាប់កាទូច ដែលអង្គុយក្បែរថា៖

-ភ្នំពេញឥឡូវឡានច្រើនទៅៗ រកផ្លូវបើកគ្មាន។ ហើយមានអ្នកបើកតិចណាស់ដែលគោរពច្បាប់។ មើលយ៉ាងអាគាត់ណឹង វាបើកពាសណាពាសណី បើជ្រុលទៅបុកគេ វាបើករត់ វាគ្មានគិតអីទេ។ ភ្នំពេញឥឡូវឃើញគ្រោះថ្នាក់ចរាចររាល់ថ្ងៃ។

-បើសិនអោយវា ទៅបររទេះគោវិញ ច្បាប់ជាក្រឡាប់បាក់ករមិនខាន។ (កាទូចបន្ថែម)។ លុះដល់កន្លែងធ្វើឡាន កាទូចដើរចូលទៅសួរអ្នកធ្វើការទីនោះ ក្រែងបានដំនឹងខ្លះពីប្តី ភាគច្រើនសុទ្ធតែអ្នកភូមិព្រៃកប្រសប់គ្នាឯង។ នាយម៉ាប់ដើរតុកៗ តាមក្រោយទៅដែរ។ ម្នាក់ទំនងជាដឹងរឿងខ្លះបាននិយាយថា៖

-ខ្ញុំធ្លាប់ជួបវាម្តង នៅហាងស៊ីផឹក។ ឃើញវាដើរជាមួយថៅកែចិន ទំនងវាធ្វើជាអង្គរក្សអោយថៅកែនោះ។



ម្នាក់ទៀតបន្ថែមថា៖

-ឮថាថៅកែនោះអោយវាខ្ចីលុយ វាបានយកលុយមកសងពួកយើងអស់ហើយ។

អ្នកមុនបន្តថា៖

-ពួកយើងមិនបានទារអីពីវាទេ តែដូចកាទូចដឹងចរិកវាហើយ វាមិនចង់ជំពាក់នរណាឡើយ។

-ចុះអត់ដឹងថាគាត់ស្នាក់នៅឯណាទេ? (កាទូចសួរ)

-វាហើរទៅយូរហើយ កាទូចអាចទៅរកវានៅហាងចិនមួយ ម្តុំផ្លូវផ្លោះអូឫស្សី។ ហាងនោះឈ្មោះវិមានក្រហម ខ្ញុំឧស្សាហ៍ឃើញវាចេញចូលទីនោះ។

កាទូចលើកដៃសំពះអរគុណ ដល់ពួកមិត្តទាំងអស់។ នាងហាក់ដូចជាអស់សង្ឃឹមក្នុងការតាមរកប្តីនាងទៅហើយ។ នាយម៉ាប់ឃើញអញ្ចឹង តាំងលួងចិត្តមិត្តថា៖

-អត់អីទេកាទូច យប់នេះចាំខ្ញុំជូនទៅហាងណឹង។ ឥឡូវយើងទៅដាក់អីវ៉ាន់នៅផ្សារច្បារអំពៅមួយភ្លែត។

-អរគុណហើយម៉ាប់

យប់ឡើងអ្នកទាំងពីរអង្គុយក្នុងឡានចាំមើលផ្លូវកន នៅមុខហាងវិមានក្រហម។ ឃើញភ្ញៀវចិនក៏មាន ភ្ញៀវខ្មែរក៏មាន ចេញចូលមិនដាច់ តែគ្មានឃើញស្រមោលកនសោះ។ មិនអស់ចិត្ត នាយម៉ាប់ឆ្លៀតចេញទៅសួរនាំអ្នកបំរើ ក្រែងគេអាចជួយប្រាប់អីខ្លះ តែគ្មានសោះ។

-ខ្ញុំមិនដែលគិតសោះ ថាប្តីខ្ញុំធ្លាក់ខ្លួនងប់នឹងល្បែង។ (កាទូចរអ៊ូរដាក់នាយម៉ាប់)

-មនុស្សប្រុស អត់មនុស្សស្រីនៅជិត ជួនកាលវង្វេងអញ្ចឹងឯង

-ខ្លួនប្រហែលជាធ្លាប់?

-ខ្ញុំធ្លាប់ ហើយខ្ញុំដឹង អាកនវាស្រលាញ់កាទូចឯងណាស់

-ឈប់និយាយទៅ ស្រលាញ់ប្រពន្ធទៅលេងល្បែងអញ្ចឹង? ខ្ញុំមិនដែលឮ

-វាធ្លាប់និយាយប្រាប់ខ្ញុំ វាថាចង់ត្រលប់ទៅស្រែវិញ។ វាថាបើយើងអ្នកស្រែមិនធ្វើ

ស្រែ  បែរជារត់មកក្រុងអស់  តើស្រុកខ្មែរបានស្រូវណាស៊ី? វាចង់បានលុយច្រើនបន្តិច  វាលែងមកវិញហើយ  វាចង់នៅជាមួយប្រពន្ធកូន។  វាចង់ធ្វើអោយកាទូចឯងសប្បាយចិត្តណឹងណា។

-ឥឡូវសប្បាយហើយ  ពុកម៉ែឯណោះជេរគាត់ផ្អើលដី

-អាកនមុខជារកផ្លូវចេញឃើញមិនខាន  ខ្ញុំស្គាល់វាច្បាស់ណាស់។

នាយម៉ាប់សំលឹងមើលនាឡិការ  ហើយស្នើរទៅកាទូចថា៖

-យប់ជ្រៅហើយ  ប្រហែលវាមិនមកទេ  យើងទៅដេកសិនទៅ

-អើ  តើខ្ញុំគួរត្រលប់ទៅស្អែក  ឬនៅរកគាត់មួយថ្ងៃទៀត?

-ខ្ញុំត្រូវដឹកអីវ៉ាន់ទៅអោយគេស្អែក  ខកមិនបានទេ  គេជេរម្រ៉ាយខ្ញុំស្លាប់ហើយ។ ទៅវិញជាមួយខ្ញុំសិនក៏បាន  ហើយចាំខានស្អែកចាំមកម្តងទៀត។

-អើ  អញ្ចឹងក៏បាន  រំខានឯងច្រើនហើយ

-រំខានអីទេកាទូចអើយ  អាកនក៏វាធ្លាប់ជួយខ្ញុំច្រើនដែរ។  តោះកុំខ្វល់  ទៅដេក។

នាយម៉ាប់បើកឡានទៅចំណត  ហើយប្រាស់ខ្លួនដេកលក់ភ្លឹង។ កាទូចដេកមិនលក់សោះ  ណានាងមិនធ្លាប់ដេកក្នុងឡាន  ណាព្រួយបារម្ភពីប្តី  ណាព្រួយបារម្ភពីកូនតូចៗផ្ទះ  ណាព្រួយពីស្រែ។  ទោះយ៉ាងណា  នាងខំសំងំបិទភ្នែកយកកំលាំង  ដើម្បីធ្វើដំនើរនៅថ្ងៃស្អែក។  កាទូចនឹកឃើញដល់គ្រាផ្សងដំនេកដំបូង  នាងមិនបានអោយកនប៉ះសាច់នាងឡើយ។  កននេះត្រូវកាទូចធាក់  ទំលាក់ធ្លាក់ពីលើគ្រែមិនដឹងជាប៉ុន្មានដង។ នៅឯស្រុកស្រែរៀបការដំបូង  ប្តីខ្លះត្រូវប្រពន្ធធាក់  ធ្លាក់ពីលើគ្រែយ៉ាងហោចណាស់បីខែ។  កាទូចនឹកដល់រឿងនេះ  លួចញញឹមម្នាក់ឯង។

ព្រឹកឡើងភ្លឺមិនទាន់  នាយម៉ាប់រួសរាន់ដើររកម៉ូយមកបង្រ្គប់  អាលនឹងចេញដំនើរ។ ម៉ាប់ទុកកៅអីមុខ  អោយកាទូចអង្គុយដាច់តែឯង។  ជាធម្មតានាយម៉ាប់ដាក់ភ្ញៀវដល់ទៅពីរនាក់ឯណោះ។  តែថាទៅនាយម៉ាប់នេះ  ធ្លាប់លួចស្រលាញ់កាទូចខ្លះដែរ។



កាទូចស្អាតដាច់គេនៅក្នុងភូមិ  នរណាៗក៏ចង់ដណ្តឹងនាងធ្វើប្រពន្ធដែរ។  កនពូកែមិនអន់ឡើយ  ទើបអាចយកឈ្នះកំលោះៗនៅក្នុងភូមិបាន។

ម៉ោងប្រមាណ៧ព្រឹក  នាយម៉ាប់រកភ្ញៀវបានគ្រប់ចំនួន។  បន្ទាប់ពីបង់លុយថ្លៃចំនតនាយប្រញាប់ប្រញាលចេញដំនើរត្រលប់ទៅភូមិវិញ។  កាទូចអង្គុយស្ងៀមក្នុងឡានមុខក្រៀមស្រពាន  រកប្តីមិនឃើញ  គ្មានម៉ាស៊ីនបូមទឹកដាក់ស្រែ។  នាយម៉ាប់បើកឡានបណ្តើរ  លួចសំលឹងមើលកាទូចបណ្តើរ។  នាយអាណិតកាទូចខ្លោចចិត្ត  តែមិនអាចជួយមិត្តអ្វីបាន។  ខ្លួនឯងរកស៊ីរាល់ថ្ងៃ  បានត្រឹមអង្ករច្រកឆ្នាំងប៉ុណ្ណោះ។ លុះជិតមកដល់ព្រៃកក្កាម  សំលេងទូរសព្ទនាយម៉ាប់រោទ៍ឡើង។  ម៉ាប់បន្ថយល្បឿនហើយទទួលទូរសព្ទ៖

-អាឡូ  អាកន!

ហេងដែរព្រោះព្រឹកមិញ  ឡានថៅកែមានបញ្ហា  កនបានយកឡានទៅធ្វើនៅហាងចាស់ដែលខ្លួនធ្លាប់ធ្វើការ។  ដល់ពេលគេប្រាប់ប្រពន្ធមករក  នាយទូរសព្ទរកម៉ាប់ភ្លាម។ កាទូចអង្គុយចាំប្តីមកទទួលនៅតូបលក់ទឹកអំពៅមួយ  នៅព្រៃកក្កាម។  នាយម៉ាប់បន្ទាប់ពីដាក់កាទូចចុះហើយ  នាយក៏បន្តដំនើរទៅទៀត។

ម៉ោងប្រមាណ១០ព្រឹក  កនបានបើកឡានថៅកែ  មកទទួលប្រពន្ធនៅព្រៃកក្កាមត្រលប់ទៅភ្នំពេញវិញ។  កនមិនហ៊ានសំលឹងមើលមុខប្រពន្ធចំឡើយ  កាទូចឯណោះដំបូងនឹកចង់ជេរប្តីអោយណាណី  ជេរអោយអស់ចិត្តក្តៅ។  តែលុះជួបប្តី  រកនឹកជេរអីមិនឃើញ    ចេះតែអង្គុយក្នុងឡានធ្វើភ្នែកភ្លើសៗ។  កនបន្លំៗសួរទៅប្រពន្ធថា៖

-ស្រីមុំមានឈឺអីទេ?

-អត់អីទេ  តែវានឹកឪវា  មិនដឹងថាឪវា  នឹកវាអត់?

កនសប្បាយចិត្តពេលប្រពន្ធតបដូច្នេះ។  តាមពិតប្តីប្រពន្ធទាំងពីរនឹកគ្នាណាស់។  កាទូចរកនឹកពាក្យជេរកនមិនឃើញ  ព្រោះនាងសប្បាយចិត្តពេកពេលបានជួបប្តី។ កនសួរបន្តទៅប្រពន្ធ៖

-ចុះពុកម៉ែ?

-ពួកគាត់សុខសប្បាយទេ តែឥឡូវខ្វះទឹកដាក់បង្ក្រប់ស្រែ។ អូនចុះមករកបង ព្រោះចង់ទិញម៉ាស៊ីនបូមទឹកមួយ។

-បងមានការងារសំខាន់មួយ ត្រូវធ្វើនៅយប់នេះ។ បើបានសំរេច បងដកខ្លួនទៅស្រែរស់នៅជាមួយអូនវិញហើយ។

-បងធ្វើអីជាមួយចៅកែចិននោះ?

-ការងារជួញដូរធម្មតាទេ អូនកុំបារម្ភអី

កាទូចដឹងថាប្តីនិយាយកុហក នាងស្គាល់កនតាំងពីតូច នាងដឹងចរិកកនជាងនរណាៗទាំងអស់។ តែថាទៅកនជាមនុស្សម៉ត់ចត់ ក្នុងការងារណាស់។ នាយមិនងាយអោយការងារច្លោះច្លោយងាយៗឡើយ។ កាទូចលែងមាត់ករ តែក្នុងចិត្តនឹកបារម្ភជួសប្តី។

-បងនាំអូនទៅស្នាក់នៅផ្ទះមិត្តបងមួយយប់សិន។ ព្រឹកស្អែកចាំបងមកទទួល។

-ផ្ទះនរណា?

-គីម បងធ្លាប់ជួយជីវិតគេម្តង។ គេជាមនុស្សល្អអាចពឹងពាក់បាន។

កនបើកឡានមកឈប់ នៅមុំមាត់ទន្លេខាងជើងវាំង។ នាយនាំប្រពន្ធឡើងទៅផ្ទះល្វែងមួយនៅជាន់ទី៣។ នេះថ្ងៃត្រង់ទៅហើយ ម្ចាស់ផ្ទះចេញមកបើកទ្វារទាំងស៊ើមមើទំនងទើបនឹងងើបពីដេក។ គីមភ្ញាក់ផ្អើលព្រោះឃើញកនៈ

-កន

-អើ នេះថ្ងៃត្រង់ហើយ ទើបភ្ញាក់? នេះកាទូចប្រពន្ធគ្នា

គីមនិងកាទូច ប្រញាប់លើកដៃ សំពះគ្នាទៅវិញទៅមក។

-ចូលម៉ោ! ចូលម៉ោ!

គីមអញ្ជើញភ្ញៀវទាំងពីរចូលផ្ទះ តែតាមពិតទៅ នេះមិនមែនជាផ្ទះគេទេ។ គីមទើបមកដល់ស្រុកខ្មែរ ពីរបីខែប៉ុណ្ណោះ។ នេះជាផ្ទះមិត្តរបស់គេ ជាជនជាតិ



បារាំង ដែលទើបរៀបការជាមួយស្រីខ្មែរ។ ហើយឥឡូវពួកគេទៅក្រេបចន្ទទឹកឃ្មុំនៅស្រុកបារាំងបាត់ហើយ ទើបពឹងអោយគីម ជួយនៅមើលថែទាំផ្ទះអោយផង។ គីមត្រលប់មកស្រុកខ្មែរ ព្រោះគេស្រមៃចង់សរសេរសៀវភៅមួយពីស្រុកខ្មែរ។ គេជាអ្នកនិពន្ធ រៀនចប់ផ្នែកអក្សរសាស្ត្រខ្មែរនៅស្រុកបារាំង។ គេមានគំនិតចង់សរសេរ សៀវភៅថ្មីមួយពីស្រុកខ្មែរ។ គេស្រមៃថ្ងៃមួយ នៅក្បែរសៀវភៅក្បាលខ្មោច ឬសៀវភៅដែលនិយាយពីការប្រល័យពូជសាសន៍ ពិភពលោកអាចរកឃើញសៀវភៅស្នេហាមួយពីស្រុកខ្មែរ។ នេះជាបំនងប្រាថ្នាដែលគេចង់ធ្វើអោយបានសំរេច ដើម្បីអោយពិភពលោកបានស្គាល់ពីស្រុកខ្មែរថ្មីមួយ។ តែយូរថ្ងៃហើយ គីមនៅមិនទាន់សរសេរអីចេញនៅឡើយទេ។

ប្តីប្រពន្ធទាំងពីរត្រូវបានគីម អញ្ជើញអោយនៅញុំាបាយរួមគ្នា។ គីមពូកែធ្វើម្ហូមណាស់ កាទូចឈរមើលគីមចំអិនអាហារ ក្នុងចិត្តកោតសរសើរថ្វីដៃរបស់គីម។ គីមញញឹមដាក់កាទូច ហើយនិយាយថាៈ

-កុំឆ្ងល់អី ប៉ាខ្ញុំជាម្ចាស់ហាងខ្មែរល្បីល្បាញមួយនៅស្រុកបារាំង។ ខ្ញុំជួយគាត់ជាង១០ឆ្នាំហើយ។

-ឯងពូកែធ្វើម្ហូបមែន (កនលាន់ម៉ាត់សរសើនៅតុបាយ)

-បង្រៀនខ្ញុំខ្លះផង ក្រែងខ្ញុំអាចបើកហាងមួយនៅឯស្រែបាន (កាទូចសុំទៅគីម)

-មានអី តែត្រូវនិយាយពីរឿងអ្នកទាំងពីរប្រាប់ខ្ញុំ

-រឿងអី? (កាទូចសួរ)

-គឺរឿងស្នេហារបស់អ្នកទាំងពីរ

-ឆ្កួតហើយ (កនលាន់ម៉ាត់)

-ខ្ញុំចង់សរសេររឿងខ្លីមួយដាក់ប្រលង បានរង្វាន់ដល់ទៅ២០០ដុល្លាឯណោះ

-ច្រើនម្លឹងផង (កាទូចបញ្ជាក់)

-អូនឯងកុំឆ្កួតតាមវា (កនប្រាប់ប្រពន្ធ)។ អាហ្នឹងវាអង្គុយសរសេរយូរទៅ

បែបចង់បែកធ្មេង

-អត់ឆ្កួតទេ ខ្ញុំចង់សរសេរពីស្រុកស្រែ សរសេរពីស្នេហាជនបទ។ ខ្ញុំចង់ប្រាប់គេឯងថា ស្រុកខ្មែរក៏មានស្នេហាដែរ ស្រុកខ្មែរមិនមែនជាវាលពិឃាតទៀតទេ។

-អូនឯងញុំបាយទៅ កុំរវល់នឹងវា រាល់ដងអោយតែវាសួរបង បងឈឺក្បាលណាស់។ ញុំបាយទៅ!

កាទូចអស់សំនើចនឹងគីម ពេលឃើញនាយប្រុងនិយាយបន្ត តែត្រូវទុចងក់ទៅវិញព្រោះតែសំដីកន។ កនលុះបាយចប់ និយាយផ្តាំផ្ញើប្រពន្ធនិងគីមរួចក៏បើកឡានចេញទៅ។ លុះបើកបានបន្តិច ស្រាប់តែមានឡានមួយវ៉ាពីខាងស្តាំ យ៉ាងលឿនស្លេវ។ កនប្រញាប់លូកដៃ ទៅកាន់កាំភ្លើងនៅក្រោមពូកឡាន។ ឡាននោះបើកមកទន្ទឹមឡានរបស់កន ហើយក៏ហួសទៅ។ គ្រាន់តែជាឡានអាឈ្លើយមួយ បើកមិនដឹងខ្យល់អីប៉ុណ្ណោះ។ កនដកដៃមកវិញ ហើយជេរអាអ្នកបើកនោះជាប់រដឹក។

កាទូចពេលប្តីចេញផុត នាងមានអារម្មណ៍ភ័យព្រួយ ខ្លាចក្រែងប្តីទៅធ្វើរឿងខុសច្បាប់ ត្រូវគេចាប់ដាក់គុកជាប់ឡោះជាប់ច្រវ៉ាក់។ នាងអង្គុយមិនស្ងៀម ដេកមិនស្រណុក នឹកចង់អុជធូបបន់ទេវតា តែក្នុងផ្ទះគ្មានកន្លែងបូជាព្រះសោះ។ នាងដាច់ចិត្ត សួរទៅគីម ដែលកំពុងអង្គុយសរសេររឿង៖

-ខ្ញុំចង់អុជធូប

គីមនាំកាទូចទៅអុជធូប នៅព្រះអង្គដង្កោរមុខវាំង។ កាទូចបានធូបមួយដុំអុជហុយផ្សែងទ្រលោម។ នាងលុតជង្គង់សំពះទេវតា ហើយបន់ស្រន់សុំអោយគ្រោះកាចចង្រៃចេញអោយឆ្ងាយពីប្តីនាង។ ឮគេថាព្រះអង្គដង្កោរសក្តិសិទ្ធិណាស់ ប្រាថ្នាអ្វីបានណឹងដូចបំនង។ ល្ងាចបន្តិចគីម នាំកាទូចដើរចូលផ្សារ Pencil ទិញគ្រឿងគ្រៅដើម្បីរៀនធ្វើម្ហូប។ មកដល់ផ្ទះ អ្នកទាំងពីរធ្វើម្ហូបបណ្តើរ គីមឆ្លៀតសួរពីរឿងរ៉ាវរបស់កាទូចនិងកនបណ្តើរ។ កាទូចត្រូវគីមសួរប៉ះសំនួរ នាងនិយាយហូរហែរតាំងពីចង្រ្កានរហូតដល់តុបាយ។ និយាយគ្នាតាំងពីថ្ងៃមិនទាន់លិច រហូតដល់យប់ជ្រៅ។



លុះដល់កាទូចនិយាយចប់ គីមភ្ញាក់ព្រើត ហើយសង្ស័យថា៖

-តើវាទៅធ្វើអីហ៎? វាមិនដែលនិយាយអីប្រាប់ខ្ញុំសោះ។ បើវាត្រូវការលុយខ្ញុំមានខ្លះដែរ ទោះមិនច្រើនតែក៏អាចជួយវាបានខ្លះដែរ។

-គាត់មិនចូលចិត្តជំពាក់នរណាទេ (កាទូចតប)

-ឆ្កួតមែន! យើងទៅរកវាទៅ។ មែនហើយ តើទៅរកវានៅឯណា?

ពួកគេក្រោយពីបាយទឹករួច ទៅអង្គុយក្នុងឡាន នៅមុខហាងវិមានក្រហមរហូតដល់គេបិទទ្វារ។ គីមចេះតែបើកឡាន ពីផ្លូវមួយទៅផ្លូវមួយពេញភ្នំពេញ។ លុះបើកអស់ចិត្ត រកកនមិនឃើញ ពួកគេក៏ត្រលប់មកផ្ទះវិញ។ កាទូចលែងម៉ាត់ករ ចូលទៅអង្គុយនៅកៅអីភ្នាក់ដៃមួយ នៅរានហាលខាងមុខផ្ទះ។ គីមទាញក្រដាស់មកសរសេរ ជួនបន្ទាប់ពីអានហើយ មិនពេញចិត្តគីមមូរវាចោលហើយចាប់ផ្តើមសរសេរឡើងវិញ ជួនពេញចិត្ត ក៏ចាប់យកសន្លឹកថ្មីមកសរសេរត។ គេសរសេររៀបរាប់ដែលមានជាអាទន័ថា៖

នេះមិនមែនជាសៀវភៅនិយាយពីសង្រ្គាម ឬពីរឿងប្រលយ័ពូជសាសន៍ហើយរឹតតែមិនមែនជាសៀវភៅនយោបាយ។ នេះជាសៀវភៅស្នេហា ជាសៀវភៅរៀបរាប់ពីជីវិតស្ត្រីខ្មែរម្នាក់។ ផ្ទុយពីសៀវភៅទាំងអស់ ដែលលោកអ្នកធ្លាប់អាន សៀវភៅតូចនេះ នឹងព្យាយាមផ្តល់ជូនលោកអ្នកបន្តិចបន្តួច ពីស្ថានភាពស្រុកខ្មែរនាពេលបច្ចុប្បន្ន។ ហើយដែលអាចនឹងធ្វើអោយលោកអ្នក សំលឹងមើលមកស្រុកខ្មែរនៅក្នុងក្រសែភ្នែកមួយ ដែលលោកអ្នកមិនធ្លាប់មាន។

នាងកំពុងអង្គុយនៅលើកៅអីភ្នាក់ដៃនោះ។ នាងអង្គុយយូរហើយ ជួននាងសំលឹងមើលទឹកទន្លេ ជួននាងសំលឹងមើលព្រះច័ន្ទ តែខ្ញុំដឹងថានាងកំពុងរងចាំប្តីរបស់នាង។ នាងមិនម៉ាត់មិនករអីទេ បើសិនខ្ញុំជានាង ម្ល៉េះសមខ្ញុំនិយាយពាក្យខ្លះចេញមកដើម្បីអោយបានធូរចិត្ត។តែនាងពូកែ ខ្ញុំសរសើរនាង។ ទោះរឿងរ៉ាវច្រើនយ៉ាងនេះ

នាងនៅតែអាចលាក់ទុកក្នុងចិត្តបាន។ ដូចពាក្យចាស់ខ្មែរ លោកពោលថា ស្ត្រីអាចទូលថ្មធំមហិមាបាន។ ខ្ញុំជឿហើយ។

មិនដឹងថាប្ដីនាងត្រលប់មកវិញទេ នៅព្រឹកស្អែក? បើព្រឹកឡើងមិនឃើញគេម៉ោ គេផ្ដាំអោយខ្ញុំជូនប្រពន្ធគេទៅស្រែវិញផង។ គេទៅធ្វើរឿងសំខាន់មួយនៅយប់នេះ គឺដើម្បីលោះបំណុលទាំងអស់ដែលគេជំពាក់។ ខ្ញុំនៅសល់លុយខ្លះដែរ តែគេមិនទទួល ចរិករបស់គេគឺមិនជំពាក់គុណនរណាឡើយ។ ខ្ញុំជំពាក់គុណគេម្ដង ក៍ព្រោះតែខ្ញុំឆ្កួតឡប់ ទៅស្រលាញ់ស្រីប៉ះលើសង្សារអ្នកដទៃ វិសត្រូវគេបាញ់នៅកន្លែងស៊ីផឹក បានគេជួយម្ដង ខ្ញុំស្បថឈប់ស្រលាញ់ស្រីហើយជាតិនេះ។ តែកុំនិយាយអីរឿងខ្ញុំចាំពេលក្រោយ។

កាទូច

វគ្គទីបី

ទន្លេសាបពេលរាត្រី ស្រស់ស្អាតមិនចាញ់អីពីទីក្រុងប៉ារីសឡើយ។ ខ្យល់មូសុងបក់មកត្រសៀកៗ ផាត់ទឹកទន្លេអោយមានរលកតិចៗរំលេចដោយពន្លឺផ្លេកៗដែលបានមកពីពន្លឺភ្លើងគោម តាមដងទន្លេចាំងផ្លាតទៅលើផ្ទៃទឹក។ កាទូចស្រាប់តែពេលនាងមានអារម្មណ៍នឹកដល់ប្ដីនាងយ៉ាងខ្លាំង។ តាំងពីណាពីណីមក នាងមិនដែលនឹកដល់ទេរឿងស្នេហាអីនោះ។ តែតាំងពីបាននិយាយរឿងរ៉ាវប្រាប់គីមមក នាងមានអារម្មណ៍ថាមានរឿងជាច្រើន ដែលនាងចង់និយាយប្រាប់ប្ដីនាង។ ពាក្យពេជន៍ជាច្រើនស្រាប់តែចេញមកក្នុងចិត្តរបស់នាង នាងបន់អោយតែថ្ងៃឆាប់រះអាល់នាងនឹងបាននិយាយពាក្យទាំងនោះប្រាប់ប្ដីនាង។ នាងចង់ប្រាប់កនថា៖អូនស្រលាញ់បង អូនស្រលាញ់បងណាស់បងកនអើយ។ តែតើកននៅឯណា?កាទូចនឹកព្រួយចិត្តខ្លាចមិនបាននិយាយពាក្យទាំងនោះប្រាប់កន។ នាងសោកស្ដាយពេលវេលាទាំងប៉ុន្មានដែលនាងមាន នាងគួរនិយាយពាក្យទាំងនោះចេញមកយូរហើយ។ កាទូចស្រមៃ



បើសិនជាកនស្ដាប់ពាក្យទាំងនោះ គេប្រាកដជាសប្បាយចិត្ត។ កាន់តែនឹកនាងកាន់តែយំ នាងយំឡើងរលីងរលោងទឹកភ្នែកហូរជោកថ្ពាលទាំងគូ។ សំណាងហើយនាងអង្គុយនៅរានហាងខាងមុខម្នាក់ឯង គីមកំពុងអង្គុយសរសេររឿងនៅខាងក្នុងឯណោះ កុំអីនាងខ្មាស់គីមស្លាប់ហើយ។
ព្រឹកឡើងស្នូរគោះទ្វារបានបន្លឺឡើង គីមភ្ញាក់ទាំងមមើលមមាយទៅបើកទ្វារ។ កនប្រាកដខ្លួននៅមុខទ្វារ កាទូចស្ទុះទៅអោបប្ដីដោយក្ដីរំភើបញាប់ញ័រ។គីមសំលឹងមើលប្ដីប្រពន្ធទាំងពីរអោបគ្នា ដោយក្ដីរីករាយក្នុងចិត្ត។
-អូនស្រលាញ់បង អូនស្រលាញ់បងណាស់ កុំទៅណាចោលអូនទៀត (កាទូចខ្សឹបដាក់ត្រចៀកប្ដីតិចៗ)
កនសំលឹងមើលមុខគីម ព្រោះតាំងពីរៀបការមក កាទូចមិនដែលចេះអីនិយាយពាក្យទាំងនេះឡើយ។ គីមលើកដៃទាំងពីររេ ប្រាប់ថាគេមិនបានធ្វើអ្វីឡើយ។ តែកនដឹង ទោះតិចឬច្រើន នេះមកពីអ្នកនិពន្ធត្បាញអាយនេះមិនខាន។ គេសប្បាយចិត្តអរគុណទៅគីម ហើយនាំប្រពន្ធត្រលប់ទៅស្រែវិញ។ គីមឃាត់អ្នកទាំងពីរអោយចាំគេបន្តិច គេដកលុយ២០០ ដុល្លារអោយទៅកន៖
-នេះសំរាប់ទិញម៉ាស៊ីនបូមទឹក
-ខ្ញុំមិនយកទេ (កនបដិសេដ)
-ឯងយកទៅ នេះមិនមែនជាលុយខ្ញុំទេ តែជាលុយដែលបានមកពីសៀវភៅនោះ គីមចូលទៅយកក្រដាស់សំនេរទាំងប៉ុន្មាន ដែលគេអង្គុយសរសេរយប់មិញមកបង្ហាញកននិងកាទូច។
-ឯងសង្ស័មថាឈ្នះរង្វាន់ដែរ?
-ឯងគិតថាខ្ញុំអន់ណាស់ទៅ? យកទៅ ខ្ញុំក៏មិនចង់ជំពាក់គុណនរណាដែរ ឯងជួយខ្ញុំម្ដងខ្ញុំជួយឯងវិញមិនបាន?
កនទទួលលុយពីគីម ហើយអោបលាមិត្តជាចុងក្រោយ។ កាទូចសំពះលាគីម នាងផ្ដាំគីមថា៖

-ទៅលេងនឹងពួកខ្ញុំផង បើមានពេល។ កុំភ្លេចយករឿងអោយខ្ញុំអាន!
-ចាំខ្ញុំទៅលេង (គីមតបទៅវិញ)
បន្ទាប់ពីប្តីប្រពន្ធកនចេញផុត គីមសំងំដេកមួយសន្ទុះព្រោះពីយប់មិញគេអង្គុយសរសេររឿងដល់យប់ជ្រៅមែនទែន។ បន្ទាប់ពីនោះគេដើបមុជទឹក ហើយស្លៀកពាក់យ៉ាងស្អាតបាត។ ក្រោយពីគ្រេបកាហ្វេរមួយកែវហើយ គីមកាន់សៀវភៅរឿងកាទូចយ៉ាងណែននៅក្នុងដៃ។ នាយយករឿងដែលសរសេរនោះទៅដាក់ប្រលងនៅសមាគមអ្នកនិពន្ធខ្មែរ ដែលស្ថិតនៅក្នុងវត្តបុទមវត្តីមិនឆ្ងាយអីពីផ្ទះនាយឡើយ។
គេដើរចុះពីផ្ទះហើយបន្តដំនើរតាមផ្លូវសុធារស ឆ្លងកាត់មុខវាំងហើយនិងសួនច្បារមុខវត្តបុទុមវត្តី លុះដល់ផ្លូវមុខវត្តនាយក្រលេកមើលឆ្វេងស្តាំដើម្បីឆ្លងថ្នល់។ នៅខាងឆ្វេង មានឡានពីរកំពុងបើកបន្តកន្ទុយគ្នា អាមួយបើកក្រោយមិនដឹងវាប្រញាប់ទៅរកខ្មោចអី វាតាំងវ៉ាគេពីឆ្វេង លុះវ៉ាខាងឆ្វេងមិនបាន វាតាំងវ៉ាពីស្តាំទាំងទទឹងទិស។ គ្រាន់តែក្បាលឡានចេញមកខាងស្តាំ វាវ៉ាក់អីជាមួយគីមដែលដើរឆ្លងមកពីរបីជំហានមកហើយ។ វាខំចាប់ហ្វ្រាំងតែដោយសាតែល្បឿនដែលវាប្រឹងវ៉ាគេនោះលឿនពេក វាមិនអាចឃាត់ឡានអោយនៅឈប់មួយកន្លែងបាន។ ខ្លួនគីមត្រូវកំលាំងឡានបុកខ្ទាត់ទៅមុខពីរបីត្រលប់។ ក្រដាស់សំនៅរឿងកាទូចហើរព្រោងព្រាតពេញថ្នល់។ អាឡានដែលបុកគីមប្រញាប់សាងលេខ ដាក់មេផាយរត់យកប្រាស់អាយុ។ វាមិនខ្វល់ទាំងយកភ្នែកមើលគីម ដែលកំពុងប្រកាច់ត្រដរខ្យល់នោះឡើយ។ អ្នកដំនើរខ្លះឈប់ ប្រញាប់រត់មកជួយមើលខ្លះហៅឡានពេទ្យ ខ្លះជួយលើកនាយទៅដាក់នៅចិញ្ចើមថ្នល់ រង់ចាំឡានពេទ្យ។ គីមលែងកំរើកខ្លួនទៅហើយ ឈាមចាប់ផ្តើមហូរចេញពីក្បាលនាយមិនឈប់។ អ្នករត់ម៉ូតូឌុបម្នាក់ដើរប្រមែប្រមូលក្រដាស់ ដែលហើរទីណាត់ទីណែងពេញថ្នល់។ បន្តិចក្រោយមកឡានពេទ្យមកដល់ តែហួសពេល គីមស្លាប់បាត់ហើយ។ គេស្លាប់ដោយបិទភ្នែកមិនជិត គេស្លាប់ដោយគ្មានហេតុផល។ គីមនឹកស្រមៃចង់



សរសេរសៀវភៅមួយ ដែលមិនប្រលាក់ឈាម។ នាយអាម៉ាស់ព្រោះឃើញតែសៀវភៅដែលនិយាយតែពីរឿងប្រល័យពូជសាសន៍ ពីវាលពិឃាត។ នាយចង់សរសេរសៀវភៅថ្មីមួយ គឺរឿងកាទូចនេះឯង។
ឥឡូវរឿងកាទូចនេះ ត្រូវប្រលាក់ដោយឈាមរបស់គីមដដែល។
មនុស្សម្នានៅកកកុញពេញមុខវត្ត ពួកគេមិនរំសាយទៅណាសោះ។ គេចាំរហូតដល់អ្នករត់ម៉ូតូឌុបនោះ ប្រមែប្រមូលក្រដាស់ទាំងអស់ ហើយរៀបតាមលំដាប់លំដោយ។ គេរង់ចាំស្តាប់តើគីមសរសេរពីអ្វី? អ្នករត់ម៉ូតូឌុបចាប់ផ្តើមអានទំព័រទីមួយ ដែលនៅប្រលាក់ឈាមម្ចាស់អ្នកសរសេរស្រស់ៗនៅឡើយ៖

នេះមិនមែនជាសៀវភៅនិយាយពីសង្គ្រាម ឬពីរឿងប្រលយ័ពូជសាសន៍ហើយរឹតតែមិនមែនជាសៀវភៅនយោបាយ។ នេះជាសៀវភៅស្នេហា ជាសៀវភៅរៀបរាប់ពីជីវិតស្ត្រីខ្មែរម្នាក់ .............

កាទូច

អាវសានកថា ឬសេចក្តីបញ្ចប់

ស្អែកឡើងនៅលើទំព័រកាសែតក្នុងស្រុក មានរូបថតគីមដេកស្លាប់នៅលើថ្នល់ជាមួយនឹងសំនៅរឿងរបស់ខ្លួន។ នៅក្បែរនោះដែរមានដំនឹងឃាតកម្មទៅលើថៅកែចិនមកពីតៃវ៉ាន់ តាមការសន្និដ្ឋានរបស់ប៉ូលីស នេះប្រហែលជាការជំរះបញ្ជីគ្នាទៅវិញទៅមករបស់ពួកម៉ាហ្វីយ៉ា(mafia)ចិនដីគោក។
កននិងកាទូចក្រោយពីអានដំនឹងក្នុងកាសែត នឹកអាណិតមិត្តខ្លោចចិត្ត មិនគួរគីមអាយុខ្លីយ៉ាងនេះ។
កាទូចអុជធូបបន់ស្រន់ សុំអោយវិញ្ញាក្ខន្ធគីមបានទៅកាន់សុខគតិភព។

តាមរបាយការណ៍អង្គការជនពិការអន្តជាតិ មានមិនតិចជាង៤០០០០ករណីគ្រោះថ្នាក់ចរាចរក្នុងមួយឆ្នាំៗនៅស្រុកខ្មែរ ក្នុងនោះ៤៥០១កើតឡើងនៅភ្នំពេញហើយមានមនុស្ស១០៤២បានស្លាប់ព្រោះគ្រោះថ្នាក់ចរាចរនៅឆ្នាំ២០០៤។

ចប់ដោយបរិបូណ៌